រក្សាសិទ្ធិ © ពត៌មាន :
© ២00១ Project WorldReach © ២00១ SEAN
រក្សាសិទ្ធិគ្រប់យ៉ាង

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

Project WorldReach (T&M™ ព័ន្ធកិច្ចប្រតិបត្តិការ)
Dr. George Patterson, (អ្នកនិពន្ធកម្មវិធី)
SEAN អន្តរជាតិ

អាស័យដ្ឋានសំរាប់ទាក់ទង :
Project WorldReach PWR ™
474 - 800 - 15355 - 24th Ave
Surrey BC, Canada
V4A 2H9

E-mail: pwr@trainandmultiply.com
Website: http://www.trainandmultiply.com

007KH01A-01

អត្ថបទសិក្សា ទី ៧

ការប្រតិបត្តិតាមព្រះអម្ចាស់យេស៊ូគ្រីស្ត



កូនស្បៃរំភៅសំរាប់បង្ហាត់បង្រៀនគ្រួគង្វាល

៧

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

T&M ™

បង្កើតសាវ័កថ្វាយព្រះយេស៊ូគ្រីស្ត

...ព្រះយេស៊ូគង់បង្រៀនបណ្តាជនពីក្នុងទូក ។ លុះព្រះអង្គ បង្រៀនគេចប់ហើយ ទ្រង់មានព្រះបន្ទូលទៅកាន់លោកស៊ីម៉ូន ថា÷ «ចូរបង្ហើសទូកទៅទីកជ្រៅ រួចនាំគ្នាទម្លាក់អួនចុះ» ។

លោកស៊ីម៉ូនតបទៅព្រះយេស៊ូវិញថា÷ «លោកគ្រូ ! យើងខ្ញុំបាន អួសអួនពេញមួយយប់ហើយ អត់បានត្រីសោះ ប៉ុន្តែ បើលោកគ្រូ មានប្រសាសន៍ដូច្នេះ ខ្ញុំនឹងទម្លាក់អួនតាមពាក្យរបស់លោកគ្រូ»។ គេក៏ទម្លាក់អួនទៅក្នុងទឹក ជាប់ត្រីយ៉ាងច្រើនស្ទើរតែធ្លាយអួន ។ គេបក់ដៃហៅមិត្តភក្តិ ដែលនៅក្នុងទូកមួយទៀតអោយមកជួយ ។ ពួកនោះមកដល់ជួយចាប់ត្រីដាក់ពេញទូកទាំងពីរស្ទើរតែនឹងលិច ។

ពេលលោកស៊ីម៉ូនពេត្រុសសិលាឃើញដូច្នោះ គាត់ក្រាបទៀប ព្រះបាទាព្រះយេស៊ូទូលព្រះអង្គថា÷«ព្រះអម្ចាស់អើយ សូមយាង អោយឆ្ងាយពីទូលបង្គំទៅ ព្រោះទូលបង្គំជាមនុស្សបាប» ។ លោកស៊ីម៉ូននិយាយដូច្នេះ ព្រោះគាត់ និងអស់អ្នកដែលនៅ ជាមួយភ័យស្ញប់ស្ញែងជាខ្លាំង នៅពេលបានឃើញត្រីច្រើនយ៉ាង នេះ ។ រីឯលោកយ៉ាកុប និង លោកយ៉ូហានជាកូនលោក សេបេដេដែលនេសាទរួមជាមួយលោកស៊ីម៉ូន ក៏មានចិត្តដូច្នោះ

កិច្ចការដែលត្រូវអនុវត្ត

- ប្រើរូបភាពបំភ្លឺ ដើម្បីនិយាយប្រាប់គ្រួសារ និងមិត្តភក្តិ របស់អ្នកអំពីរបៀបដែលព្រះយេស៊ូត្រាស់ហៅសិស្សរបស់ ទ្រង់ ។
- ផ្សាយដំណឹងល្អប្រាប់មិត្តភក្តិរបស់អ្នក ហើយជួយបងប្អូន ដែលជឿថ្មីលើព្រះគ្រីស្តរបស់អ្នក អោយធ្វើតាមសេចក្តី បង្គាប់គ្រប់យ៉ាងរបស់ព្រះអង្គ ។

បានសិក្សាអត្ថបទនេះ និងបានធ្វើកិច្ចការដែលត្រូវអនុវត្តរួចហើយ

_____ _____

(ថ្ងៃ ខែ) (ហត្ថលេខារបស់គ្រូបង្ហាត់)

© Project WorldReach © SEAN

សូមទន្ទេញ

«ព្រះអង្គមានព្រះបន្ទូលទៅគេថា៖ "ចូរនាំគ្នាទៅគ្រប់ទីកន្លែងក្នុងពិភពលោក ហើយប្រកាសដំណឹងល្អដល់មនុស្សលោកទាំងអស់" ចុះ » ។ (ម៉ាកុស ១៦:១៥)

នៅពេលដែលអ្នកផ្សព្វផ្សាយដំណឹងល្អ សូមនិយាយរៀបរាប់ពីចំណុចទាំងបីរបស់ដំណឹងល្អនេះ :

១- ជីវិត ការអស្ចារ្យ និងសេចក្តីបង្រៀនរបស់ព្រះយេស៊ូគ្រីស្ត ។

២- ព្រះយេស៊ូសុគតដើម្បីលោះយើងពីបាប ហើយមានព្រះជន្មរស់ឡើងវិញ ដើម្បីប្រទានជីវិតអស់កល្បដល់យើង ។

៣- ការចាំបាច់ត្រូវតែកែប្រែចិត្តគំនិត ជឿលើព្រះអម្ចាស់យេស៊ូគ្រីស្ត និងទទួលពិធីជ្រមុជទឹក ដើម្បីអោយព្រះជាម្ចាស់លើកលែងទោសយើងអោយរួចពីបាប និងដើម្បីទទួលព្រះវិញ្ញាណដ៏វិសុទ្ធ ។

ដែរ ។ ប៉ុន្តែ ព្រះយេស៊ូមានព្រះបន្ទូលទៅលោកស៊ីម៉ូនថា៖ «កុំខ្លាចអី ! ពីពេលនេះទៅមុខ អ្នកនឹងនេសាទមនុស្សវិញ » ។

(លូកា ៥:១-១១)

បន្ទាប់មក ព្រះយេស៊ូយាងឡើងទៅលើភ្នំ ។ ព្រះអង្គបានត្រាស់ហៅអស់អ្នកដែលព្រះអង្គសព្វព្រះហឫទ័យជ្រើសរើស ហើយអ្នកទាំងនោះក៏ចូលមកគាល់ព្រះអង្គ ។ ព្រះអង្គតែងតាំងសាវ័កដប់-ពីររូបអោយគេនៅជាមួយព្រះអង្គ និងដើម្បីចាត់គេអោយទៅប្រកាសដំណឹងល្អ ទាំងអោយគេមានអំណាចដេញអារក្សថែមទៀតផង ។

ព្រះអង្គបានតែងតាំងអ្នកដប់ពីររូបនេះ គឺស៊ីម៉ូនដែលទ្រង់ដាក់ឈ្មោះថា ពេត្រុសសិលា យ៉ាកុបជាកូនរបស់លោកសេបេដេ និងយ៉ូហានជាប្អូនរបស់គាត់ ដែលព្រះយេស៊ូដាក់ឈ្មោះថា «បោណើកែស » ប្រែថា "អ្នកដែលមានចិត្តខ្លាំងដូចផ្គរលាន់" អន់ដ្រេ ភីលីព បាថូឡូមេ ម៉ាថាយ ថូម៉ាស យ៉ាកុបជាកូនអាល់ផាយ ថាដេ ស៊ីម៉ូនជាអ្នកជាតិនិយម និងយូដាសអ៊ីស្ការីយ៉ុតជាអ្នកក្បត់ព្រះអង្គ ។

(ម៉ាកុស ៣:១៣-១៩)

ព្រះយេស៊ូមានព្រះបន្ទូលថា÷ «ខ្ញុំអោយវិន័យថ្មីដល់អ្នករាល់គ្នា គឺ ត្រូវស្រឡាញ់គ្នាទៅវិញទៅមក ។ អ្នករាល់គ្នាត្រូវស្រឡាញ់គ្នាទៅ វិញទៅមក ដូចខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ ។ បើអ្នក ស្រឡាញ់គ្នាទៅវិញទៅមក មនុស្សទាំងអស់មុខជាដឹងថា អ្នករាល់ គ្នាពិតជាសាវ័ករបស់ខ្ញុំមែន » ។ (យ៉ូហាន ១៣:៣១-៣៥)

ក្រោយពីព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញហើយ :

សាវ័កទាំងដប់មួយរូប នាំគ្នាធ្វើដំណើរទៅស្រុកកាលីឡេ ហើយ ឡើងទៅលើភ្នំដែលព្រះយេស៊ូបានប្រាប់អោយគេទៅ ។ កាលគេ បានឃើញព្រះអង្គ គេក្រាបថ្វាយបង្គំ ប៉ុន្តែ មានអ្នកខ្លះនៅ សង្ស័យ ។ ព្រះយេស៊ូយាងចូលមកជិតគេ ហើយមានព្រះបន្ទូល ថា÷ «ខ្ញុំបានទទួលគ្រប់អំណាច ទាំងនៅស្ថានបរមសុខ ទាំងនៅ លើផែនដី ។ ដូច្នេះ ចូរចេញទៅនាំមនុស្សគ្រប់ជាតិសាសន៍ អោយធ្វើជាសាវ័ក ហើយធ្វើពិធីជ្រមុជទឹកអោយគេក្នុងព្រះនាម ព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ ។ ត្រូវបង្រៀនគេ អោយប្រតិបត្តិតាមសេចក្តីទាំងប៉ុន្មាន ដែលខ្ញុំបានបង្គាប់អ្នករាល់ គ្នា ។ ចូរដឹងថា ខ្ញុំនៅជាមួយអ្នករាល់គ្នាជារៀងរាល់ថៃ រហូត ដល់អវសានកាលនៃពិភពលោក » ។ (ម៉ាថាយ ២៨:១៦-២០)

ហេតុអ្វីបានជាលោកពេត្រុសលុតជង្គង់ នៅចំពោះព្រះភ័ក្ត្រ ព្រះអម្ចាស់យេស៊ូគ្រីស្តនៅក្នុងទូក ?

ចាប់ពីពេលនោះទៅ តើលោកពេត្រុសត្រូវ «នេសាទ»អ្វីវិញ ?

ព្រះអម្ចាស់យេស៊ូគ្រីស្តបង្គាប់សិស្សរបស់ព្រះអង្គ អោយដើរតាម ព្រះអង្គ ដោយធ្វើពលិកម្មគ្រប់យ៉ាង ដោយធ្វើតាមសេចក្តីបង្គាប់ គ្រប់យ៉ាងរបស់ព្រះអង្គ និងដោយស្រឡាញ់គ្នាទៅវិញទៅមក ។

តើអ្នកនឹងជួយអ្នកណាឱ្យក្លាយទៅជាសាវ័កស្មោះត្រង់របស់ព្រះ-គ្រីស្ត ? សូមសរសេរឈ្មោះសាច់ញាតិ ឬ មិត្តភក្តិពីរបីនាក់ ដែលអ្នកនឹងជួយ :

© Project WorldReach © SEAN